# ពាណិជ្ជករទីក្រុងវេនីស

## មិត្តភក្តិដ៏ល្អម្នាក់

នៅក្នុងថ្ងៃពេលដែលទីក្រុងវេនីសសំបូរសប្បាយ និងល្បីល្បាញនោះ ម្នាក់ក្នុងចំនោមប្រជាពលរដ្ឋដែលជាថៅកែគេមានពាណិជ្ជករម្នាក់ឈ្មោះអាណូធីអូ។ គាត់គឺជាបុរសដ៏មានម្នាក់។ គាត់មានកប៉ាល់មានតម្លៃជាច្រើន ហើយធ្វើជំនួញជាមួយនឹងប្រទេសអន្តរជាតិផ្សេងៗទៀត។ គាត់មានភាពល្បីល្បាញដោយសារតែសណ្តានចិត្តល្អរបស់គាត់ ហើយមានមិត្តភក្តិជាច្រើន។ ក្នុងចំនោមពួកគេគឺជាអភិជនជនជាតិវេនិធេនវ័យក្មេងម្នាក់ឈ្មោះបាសានីអូ។

ទោះបីជាគាត់គឺជាអភិជនក៏ដោយ ក៏បាសានីអូពិតជាក្រីក្រខ្លាំងណាស់។ ជាញឹកញាប់ គាត់តែងចំនាយលុយច្រើនជាងដែលគាត់មាន អញ្ចឹងទើបគាត់អាចរស់នៅតាមវិធីដែលគាត់ចូលចិត្ត។ ប៉ុន្តែអាណូធីអូស្រលាញ់គាត់ណាស់ ហើយតែងតែឲ្យគាត់ខ្ចីលុយនៅពេលដែលគាត់ត្រូវការទៀតផង។

បាសានីអូធ្លាក់ទៅក្នុងអន្លង់ស្នេហ៍របស់នារីអភិជនវ័យក្មេងដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ឈ្មោះផតធៀ ដែលឪពុករបស់នាងទើបតែនឹងចែកឋានទៅ។ ផតធៀមិនមែនត្រឹមតែមានទ្រព្យសម្បត្តិនោះទេ នាងថែមទាំងស្រស់ស្អាត ហើយមានបញ្ញាទៀតផង។ ព្រះអង្គម្ចាស់ និងអភិជនទាំងឡាយកំពុងតែសុំនាងរៀបការជាបន្តបន្ទាប់។ បុរសទាំងនេះមានលទ្ធភាពនឹងបង្ហាញពីភាពស្តុកស្តម្ភនិងតំណែងរបស់ពួកគេដោយទៅដល់ផ្ទះរបស់នាងដោយមានអ្នកបំរើជាច្រើន ហើយឲ្យអំណោយដ៏មានតម្លៃជាច្រើនជូននាង។ បាសាអូនីមិនមានលុយគ្រប់គ្រាន់ដើម្បីធ្វើដូច្នេះឡើយ។ គាត់ខ្លាចថាផតធៀនឹងមិនពិចារណាពីការរៀបការជាមួយនឹងគាត់ទេពីព្រោះគាត់ពិតជាក្រជាងអ្នកដទៃទៀតណាស់។

អញ្ចឹងនៅថ្ងៃមួយ បាសានីអូបានទៅរកមិត្តភក្តិរបស់គាត់អាណូធីអូដើម្បីសុំរកជំនួយ។ គាត់ប្រាប់អាណូធីអូថាផតធៀហាក់ដូចជាពេញចិត្តនឹងគាត់។ បាសានីអូប្រាប់គាត់ថាប្រសិនបើគាត់គ្រាន់តែអាចទៅលេងនាងដោយស្លៀកបំពាក់នូវសម្លៀកបំពាក់ស្អាតៗ ដោយមានអ្នកបំរើជាច្រើននាក់ ហើយដោយមានអំណោយដ៏ស្រស់ស្អាតមួយចំនួនសម្រាប់ផតធៀ គាត់ប្រហែលជានឹងបានជោគជ័យ។ ប្រសិនបើអាណូធីអូឲ្យលុយគាត់ខ្ចីល្មមគ្រប់គ្រាន់ ផតធៀប្រហែលជានឹងយល់ព្រមរៀបការជាមួយគាត់។

"ខ្ញុំតែងតែស្ម័គ្រចិត្តនឹងជួយឯងជានិច្ច បាសានីអូ" អាណូធីអូនិយាយ "ប៉ុន្តែឥលូវខ្ញុំគ្មានលុយឲ្យឯងខ្ចីទេ។ ខ្ញុំយកទៅធ្វើជំនួញជាមួយនឹងប្រទេសដ៏ទៃអស់ហើយ។ ឥលូវ កប៉ាល់របស់ខ្ញុំនៅឆ្ងាយ

ហើយឯសមុទ្រឯទន់ៈ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនឹងមានលុយជាច្រើននៅពេលដែលពួកវាត្រលប់មកវិញ។ ទំរាំដល់ពេលនោះ ខ្ញុំនឹងខ្ចីលុយមួយចំនួនឲ្យឯង ពីស្យាយឡុក់។"

ស្យាយឡុក់ដែលជាជនជាតិជិហ្វមានភាពល្បីល្បាញណាស់នៅវេនីសនេះ។ គាត់ជាអ្នកចងការប្រាក់ ហើយគាត់ក្លាយទៅជាអ្នកមានស្តុកស្តម្ភម្នាក់។ គាត់ចូលចិត្តបង្កើនលុយឲ្យកាន់តែច្រើនទៅៗ ប៉ុន្តែគាត់ស្អប់ការចំនាយណាស់។

គាត់មិនមានប្រជាប្រិយភាពឡើយនៅក្នុងទីក្រុង ដោយសារតែគាត់កំណាញ់ពេក។ មនុស្សដែលមិនអាចសងលុយដែលពួកគេជំពាក់គាត់វិញបាន នឹងមិនទទួលការប្រណីពីស្យាយឡុក់ឡើយ។ ជាញឹកញាប់ អាណូធីអូបានអះអាងចំពោះអ្នកឯទៀតថាគាត់មិនមានការគោរពចំពោះស្យាយឡុក់ឡើយ ដោយសារតែវិធីដែលគាត់ចាត់ទុកមនុស្សទាំងនោះដែលខ្ចីបុលពីគាត់។ អាណូធីអូខ្លួនគាត់បានឲ្យលុយគេខ្ចីជាច្រើនដងមកហើយដោយមិនគិតពីការប្រាក់ ហើយរឿងនេះប៉ះពាល់ដល់ជំនួញរបស់ស្យាយឡុក់។ ដោយសារតែហេតុផលទាំងនេះ ស្យាយឡុក់ស្អប់អាណូធីអូ ហើយគាត់កំពុងទន្ទឹងរង់ចាំយ៉ាងសំងាត់ដើម្បីឆក់ឱកាសធ្វើបាបគាត់។

បាសានីអូទៅជាមួយអាណូធីអូដើម្បីទៅរកស្យាយឡុក់។ អាណូធីអូសុំខ្ចីលុយ៣០០០ឌុកាត់ជាចំនួនលុយដ៏ច្រើន។ "ខ្ញុំនឹងមានលទ្ធភាពបង់សងវិញ" គាត់និយាយទៅរកស្យាយឡុក់ "នៅពេលដែលកប៉ាល់របស់ខ្ញុំត្រលប់មកវេនីសវិញ។ ឥលូវពួកវានៅឯសមុទ្រ ហើយក្នុងពេលឆាប់ៗនេះ ពួកវានឹងត្រលប់មកផ្ទះវិញដោយមានរបស់របរមានតម្លៃជាច្រើន។ ដូចដែលឯងដឹងស្រាប់ហើយ ខ្ញុំមិនដែលឲ្យគេខ្ចីលុយ រឺក៏ខ្ចីលុយគេដោយសារតែផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ ប៉ុន្តែដោយសារតែបាសានីអូជាមិត្តភក្តិដ៏ជិតស្និទ្ធបំផុតរបស់ខ្ញុំ ខ្ញុំនឹងធ្វើរឿងនេះដើម្បីគាត់។"

មុនដំបូង ស្យាយឡុក់ហាក់ដូចជាមិនស្ម័គ្រចិត្តនឹងឲ្យលុយខ្ចីនោះទេ។ គាត់ដឹងច្បាស់ណាស់ថាអ្វីៗដែលអាណូធីអូនិយាយគឺជាការពិតទាំងអស់។ "កប៉ាល់របស់ឯងប្រហែលជានឹងត្រូវបានកំទេចដោយខ្យល់ព្យុះមុនពេលដែលពួកវាមកដល់វេនីស" គាត់និយាយ "ហើយអញ្ចឹងឯងនឹងគ្មានលទ្ធភាពសងលុយខ្ញុំវិញទេ។"

"បន្ទាប់មកគាត់សម្រេចចិត្តផ្តល់កិច្ចព្រមព្រៀងទៅអាណូធីអូ។ "ខ្ញុំស្ម័គ្រចិត្តនឹងធ្វើជាមិត្តជាមួយនឹងឯង ហើយខ្ញុំនឹងឲ្យឯងខ្ចីលុយដោយគ្មានគិតពីផលប្រយោជន៍អ្វីទាំងអស់។ អញ្ចឹងវានឹងបង្ហាញថាខ្ញុំក៏មានសន្តានចិត្តល្អ ហើយសប្បុរសធម៌ដែរ ផ្ទុយពីអ្វីដែលឯងបាននិយាយពីខ្ញុំ។ ប៉ុន្តែខ្ញុំមានគំនិតដ៏ល្អមួយ ហើយខ្ញុំសង្ឃឹមថាឯងនឹងយល់ព្រម។ ប្រសិនបើឯងមិនអាចសងលុយទាន់ពេលវេលាទេនោះ អញ្ចឹងឯងត្រូវតែឲ្យខ្ញុំកាត់សាច់របស់ឯងមួយផោនពីគ្រប់ផ្នែកនៃខ្លួនរបស់ឯងតាមដែលខ្ញុំជ្រើសរើស។"

បាសានីអូងឿងឆ្ងល់ពីគោលបំណងរបស់ស្យាយឡុក់ ហើយប្រាប់អាណូធីអូមិនឲ្យទទួលយកនូវគំរោងនេះទេ។ ប៉ុន្តែអាណូធីអូសើច ហើយយល់ព្រមនឹងរឿងកំប្លែងនេះ។ បន្ទាប់មកអ្នកទាំងបីក៏

ទៅរកមេធាវីម្នាក់ឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ អាណូធីអូយកលុយពីស្យាយឡុក់ ហើយឲ្យទៅបាសានីអូ ដែលរៀបចំខ្លួនរួចជាស្រេចក្នុងការទៅលេងបិលម៉ុន ដែលផតធៀរស់នៅ។

**ប្រអប់ទាំងបី**

ឪពុករបស់ផតធៀមានការព្រួយបារម្ភណាស់ពីរឿងដែលនាងគួរតែជ្រើសរើសបុរសដ៏ល្អដើម្បីធ្វើជាប្តីរបស់នាង។ មុនពេលដែលគាត់ស្លាប់ គាត់បានបង្កើតគំរោងមួយដើម្បីជួយនាងធ្វើរឿងនេះ។ គាត់បានធ្វើប្រអប់ដែកតូចៗបី។ មួយៗធ្វើពីដែកខុសៗគ្នា។ ប្រអប់ទីមួយធ្វើពីមាស ប្រអប់ទីពីរធ្វើពីប្រាក់ និងប្រអប់ទីបីធ្វើពីសំណ។ ប្រអប់មួយក្នុងចំនោមប្រអប់ទាំងបីនេះមានរូបផតធៀមួយសន្លឹក។ បុរសម្នាក់ៗត្រូវតែធ្វើការសន្យាថា ប្រសិនបើគេទាយខុស គេត្រូវតែមិនសុំនារីណាម្នាក់រៀបការជារៀងរហូតបន្ទាប់ពីនោះមក។ ផតធៀមានអារម្មណ៍ថានាងត្រូវតែស្តាប់បង្គាប់តាមឪពុករបស់នាង ទោះបីជាគាត់ស្លាប់ទៅហើយក៏ដោយ។ នាងមានការព្រួយបារម្ភថាបុរសដែលនាងមិនពេញចិត្តនឹងរកឃើញរូបរបស់នាង ប៉ុន្តែនាងនៅតែមានចេតនាធ្វើនូវអ្វីដែលឪពុកនាងឲ្យធ្វើ។

នៅពេលដែលពួកគេឮពីផែនការនេះ បុរសជាច្រើនមិនហ៊ានទាយទាល់តែសោះ ហើយពួកគេចេញទៅឆ្ងាយ។ ពួកគេខ្លាចចាញ់ណាស់ ពីព្រោះរឿងនោះមានន័យថាពួកគេនឹងមិនរៀបការរហូតទាល់តែស្លាប់។ រឿងនេះធ្វើឲ្យផតធៀសប្បាយចិត្ត ដោយសារតែនាងមិនពេញចិត្តបុរសណាម្នាក់សោះដែលមកជួបនាង។ នាងប្រាប់អ្នកបំរើរបស់នាង ឈ្មោះនេរីសា ថាពួកគេទាំងអស់មិនគួរឲ្យចាប់អារម្មណ៍សោះ រឺក៏គ្មានអារម្មណ៍កំប្លុកកំប្លែងសោះ រឺក៏តែងតែមួរម៉ៅជានិច្ច។

ម្នាក់ក្នុងចំនោមពួកគេដែលហ៊ានជ្រើសរើសគឺជាព្រះអង្គម្ចាស់មកពីប្រទេសម៉ូរ៉ុក្កូ។ គាត់ជ្រើសរើសយកប្រអប់មាស។ គាត់គិតថាមានតែប្រអប់មាសទេដែលសក្តិសមនឹងដាក់រូបថតផតធៀ។ ក៏មានសរសេរនៅខាងក្រៅប្រអប់ដែរ។ វានិយាយថា៖ "បុរសដែលជ្រើសរើសយកប្រអប់នេះនឹងទទួលបាននូវអ្វីដែលបុរសភាគច្រើនប្រាថ្នាចង់បាន។"

"អូ មានន័យថាស្ត្រីទេតើ" ព្រះអង្គម្ចាស់និយាយទៅរកខ្លួនព្រះអង្គ។ "ពិភពលោកទាំងមូលចង់បាននាង។ ពួកគេមកពីគ្រប់ជ្រុងទាំងបួននៃផែនដី ឆ្លងកាត់សមុទ្រ និងវាលខ្សាច់ គឺគ្រាន់តែចង់មកមើលផតធៀដ៏ស្រស់ស្អាតម្នាក់នេះ។ អញ្ចឹង ប្រសិនបើខ្ញុំជ្រើសរើសនូវអ្វីដែលបុរសជាច្រើនប្រាថ្នាចង់បាន វាប្រាកដជាមានន័យថារូបនាងនឹងនៅក្នុងប្រអប់នេះហើយ។" ប៉ុន្តែនៅពេលដែលព្រះអង្គបើកវាគាត់ឃើញតែរូបលលាដ៏ក្បាលមួយសន្លឹកប៉ុណ្ណោះ សម្រាប់រំលឹកព្រះអង្គពីសេចក្តីស្លាប់ ដែលគឺជាអ្វីដែលមនុស្សភាគច្រើនប្រាថ្នាចង់បាននៅពេលដែលពួកគេចាស់ជរា ហើយឈឺ និងមានទុក្ខសោក។ ព្រះអង្គពិតជាមិនសប្បាយចិត្តយ៉ាងខ្លាំង។

បុរសបន្ទាប់ដែលមកទាយគឺជាព្រះអង្គម្ចាស់នៃទីក្រុងអារ៉ាហ្គុន ប្រទេសអេស្ប៉ាញ។ ព្រះអង្គមិនជ្រើសរើសប្រអប់មាសទេ ពីព្រោះព្រះអង្គគិតថាពាក្យ "បុរសជាច្រើន" ចង់និយាយពីមនុស្សសាមញ្ញទាំងអស់នៅលើពិភពលោក។ ព្រះអង្គម្ចាស់នៃទីក្រុងអារ៉ាហ្គុនគឺជាបុរសដ៏មានមោទនភាព

ម្នាក់។ គាត់មិនដែលចង់បាននូវអ្វីដែលមនុស្សរាល់គ្នាដទៃទៀតចង់បាននោះទេ។ ជំនួសវិញ គាត់ជ្រើសរើសយកប្រអប់ពណ៌ប្រាក់។ នៅលើប្រអប់ពណ៌ប្រាក់សរសេរថា៖ "បុរសដែលជ្រើសរើសប្រអប់នេះនឹងទទួលបាននូវអ្វីដែលគាត់សក្តិសមនឹងទទួល។" រឿងនេះហាក់ដូចជាយុត្តិធម៌ណាស់ព្រះអង្គបានគិត។ គាត់ដឹងថាមានមនុស្សជាច្រើនមកជួបផតធៀដែលមិនមានលក្ខណៈសម្បត្តិល្អដូចដែលមើលឃើញពីខាងក្រៅនោះទេ។ មនុស្សទាំងនោះមិនសក្តិសមនឹងរៀបការជាមួយផតធៀនោះទេ។ ប៉ុន្តែព្រះអង្គមិនដូចពួកគេឡើយ។ ព្រះអង្គជាព្រះអង្គម្ចាស់នៃទីក្រុងអារ៉ាហ្គុន ដែលជាបុរសវ័យក្មេងដ៏សង្ហា និងយ៉ាងសំខាន់ ហើយព្រះអង្គប្រាកដណាស់ថាព្រះអង្គសក្តិសមនឹងរៀបការជាមួយប្រពន្ធដ៏ល្អ ស្រស់ស្អាត និងមានទ្រព្យដូចជាផតធៀ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងមិនមែនជារូបដ៏ស្រស់ស្អាតរបស់ផតធៀដែលគាត់រំពឹងទុកនោះទេ ប៉ុន្តែជារូបរបស់មនុស្សភ្លីភ្លើដ៏ឆ្កួតលីលាម្នាក់។ គាត់ក៏ត្រូវចេញទៅឆ្ងាយដោយខកចិត្ត។

បន្ទាប់មកផតធៀទទួលដំនឹងថាបាសានីអូបានមកដល់។ គាត់ក៏បាននាំមិត្តរបស់គាត់ឈ្មោះគ្រេនធីអានូមកជាមួយដែរ។ គ្រេនធីអានូធ្លាក់ទៅក្នុងអន្លង់ស្នេហ៍របស់នេរីសា ដែលត្រូវជាអ្នកបំរើរបស់ផតធៀ ហើយសង្ឃឹមថានឹងសុំនេរីសារៀបការជាមួយគាត់ ខណៈពេលដែលបាសានីអូកំពុងតែសុំផតធៀធ្វើជាប្រពន្ធរបស់គាត់។

នៅពេលដែលបាសានីអូបង្ហាញខ្លួនឡើង ផតធៀស្វាគមន៍គាត់យ៉ាងកក់ក្តៅ។ នាងសប្បាយចិត្តណាស់ដែលគាត់បានមកដល់ ដូចដែលនាងចង់រៀបការជាមួយគាត់។ នាងពិតជាមានការព្រួយបារម្ភណាស់ ព្រោះខ្លាចគាត់ជ្រើសរើសយកប្រអប់ខុស ដូចដែលអ្នកឯទៀតបានសាកល្បងរួចទៅហើយ។ ផតធៀចង់ជួយគាត់ឲ្យរកឃើញប្រអប់ត្រឹមត្រូវ ប៉ុន្តែនាងដឹងថានាងមិនត្រូវធ្វើអញ្ចឹងនោះទេ។ នាងស្នើសុំឲ្យបាសានីអូរង់ចាំពីរបីថ្ងៃសិនមុនពេលដែលគាត់ធ្វើការជ្រើសរើស អញ្ចឹងពួកគេក៏អាចនៅជាមួយគ្នាអស់មួយរយៈកាលដែរ។ នាងដឹងថាប្រសិនបើគាត់មានកំហុស ហើយជ្រើសរើសប្រអប់ខុស ពួកគេនឹងមិនអាចរៀបការបានទេ ហើយនាងក៏នឹងមិនដែលជួបគាត់ម្តងទៀតដែរ។ ប៉ុន្តែបាសានីអូមិនរង់ចាំឡើយ គាត់មានការព្រួយបារម្ភណាស់ ថានឹងមានអ្វីកើតឡើង។ ដូច្នេះ គាត់ក៏ត្រូវគេបង្ហាញប្រអប់ទាំងបី ធ្វើពីមាស ប្រាក់ និងសំណ។

បាសានីអូគិតអស់កាលយ៉ាងយូរ។ ចុងបញ្ចប់ គាត់ក៏សម្រេចចិត្ត។ មាស និងប្រាក់មើលទៅដូចជាមានតម្លៃ ហើយស្រស់ស្អាតណាស់ ប៉ុន្តែរបស់ជាច្រើនដែលអាក្រក់ រឺក៏គ្មានតម្លៃអ្វី អាចត្រូវគេធ្វើឲ្យមានតម្លៃហើយស្រស់ស្អាត។ សំណគឺជាដែកធម្មតា និងយ៉ាងសាមញ្ញមួយ។ វាមិនធ្វើពុតជាល្អប្រសើរជាងខ្លួនវានោះទេ គាត់បានគិត។ វាមានភាពស្មោះត្រង់។ នៅលើប្រអប់នេះមានពាក្យសរសេរថា៖ "បុរសដែលជ្រើសរើសប្រអប់នេះនឹងត្រូវទទួលបាននូវឱកាសដ៏អស្ចារ្យមួយ៖ គាត់ប្រហែលជានឹងអាចបាត់បង់នូវអ្វីដែលគាត់មាន។" វាក៏មានភាពស្មោះត្រង់ដែរ បាសានីអូបានគិត។ ដូច្នេះ គាត់ក៏ជ្រើសរើសយកប្រអប់សំណ។

ផតធៀមើលគាត់ទាយត្រូវដោយក្ដីរីករាយ។ បាសានីអូបើកប្រអប់នោះឡើង ហើយនៅខាងក្នុង គាត់ឃើញរូបរបស់ផតធៀ។ គាត់បែរទៅរកផតធៀ ហើយឃើញថានាងក៏សប្បាយចិត្ត និងរីករាយដូចគាត់ដែរ។ ភ្លាមនោះ នាងប្រាប់គាត់ថានាងពិតជាស្រលាញ់គាត់ខ្លាំងណាស់។ បន្ទាប់មកគាត់ដោះចិញ្ចៀនចេញពីម្រាមដៃរបស់នាង ហើយប្រគល់វាឲ្យទៅបាសានីអូ។ ផតធៀនិយាយថាគាត់ត្រូវតែមិនដោះវាចេញទៅណាទេ ប្រសិនបើជាគាត់ដោះវាចេញ សេចក្ដីស្នេហារបស់គេនឹងត្រូវបញ្ចប់។ បាសានីអូទទួលយកចិញ្ចៀនយ៉ាងសប្បាយចិត្ត ហើយសន្យាថានឹងមិនដែលធ្វើឲ្យវាបាត់ រឺក៏យកទៅណាឆ្ងាយនោះទេ។ ដូច្នេះ ផតធៀ និងបាសានីអូសន្យាគ្នាថានឹងស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក។

## ការកាត់ទោសអាណ្ឌូធីអូ

គ្រេនធីអានូ និងនេរីសាក៏នៅក្នុងបន្ទប់ក្នុងពេលជាមួយគ្នានោះដែរ ហើយកំពុងតែមើលថាមានរឿងអ្វីកើតឡើង។ ឥលូវ គ្រេនធីអានូដើរសំដៅមកមុខ ហើយនិយាយថាគាត់សង្ឃឹមថាផតធៀ និងបាសានីអូនឹងសប្បាយចិត្ត។ គាត់និយាយថាគាត់ និងនេរីសាចង់រៀបការនៅពេលជាមួយគ្នានោះដែរ។ ផតធៀ និងបាសានីអូពិតជាសប្បាយចិត្តណាស់ ហើយយល់ព្រមភ្លាមមួយរំពេច។

ប៉ុន្តែបន្ទាប់មក រឿងមួយបានកើតឡើងដែលធ្វើឲ្យពួកគេព្រួយបារម្ភពីកិច្ចព្រមព្រៀងដ៏អស្ចារ្យមួយ។ សារមួយបានមកដល់ជាមួយនឹងសំបុត្រមួយច្បាប់សម្រាប់បាសានីអូពីមិត្តភក្តិរបស់គាត់ អាណ្ឌូធីអូ ដែលបានខ្ចីលុយពីស្យាយឡក់ឲ្យគាត់។ មុខរបស់បាសានីអូប្រែជាស្លេកស្លាំងខណៈពេលដែលគាត់អានសំបុត្រនេះ។ វាសរសេរពីដំណឹងដ៏អាក្រក់មួយ។ ផតធៀបានសួរថាមានរឿងអ្វីកើតឡើងយ៉ាងឆាប់រហ័ស។ ហើយឥលូវ ជាលើកដំបូង បាសានីអូបានប្រាប់នាងពីរឿងលុយដែលអាណ្ឌូធីអូបានឲ្យមកគាត់។ គាត់ក៏ប្រាប់នាងពីកិច្ចព្រមព្រៀងរបស់អាណ្ឌូធីអូជាមួយនឹងស្យាយឡក់ដែរ។ នៅក្នុងសំបុត្រនេះ អាណ្ឌូធីអូនិយាយថាកប៉ាល់របស់គាត់មិនត្រលប់មកកំពង់ផែវិញទេ ពួកវាខូចនៅឯសមុទ្រ ហើយទំនិញដែលមានតម្លៃទាំងអស់ត្រូវបាត់បង់។ អាណ្ឌូធីអូគ្មានលុយសងបំណុលស្យាយឡក់ឡើយ ហើយថ្ងៃកំណត់ហួសបាត់ទៅហើយ។ គាត់នឹងត្រូវតែឲ្យសាច់របស់គាត់មួយផោន។ អាណ្ឌូធីអូបានសរសេរថា៖ "ឥលូវ ខ្ញុំប្រាកដជាស្លាប់ហើយ ហើយចង់ជួបឯងជាលើកចុងក្រោយ"។

សារនេះប្រាប់ពួកគេថាស្យាយឡក់បានទៅរកឌុចនៃទីក្រុងវេនីសដើម្បីស្នើសុំឲ្យគាត់ដោះស្រាយបញ្ហានេះ។ ស្យាយឡក់ចង់ឲ្យអាណ្ឌូធីអូសងសាច់មួយផោនរបស់គាត់ភ្លាមៗ។ ហើយឥលូវអាណ្ឌូធីអូដ៏កំសត់កំពុងតែនៅក្នុងគុក រង់ចាំថ្ងៃកាត់ទោស។

នៅពេលដែលផតធៀឮរឿងដ៏អាក្រក់នេះហើយ នាងចង់ជួយតាមវិធីគ្រប់បែបយ៉ាងដែលនាងអាចធ្វើបាន។ នាងសុខចិត្តសងស្យាយឡក់ច្រើនជាង៣០០០ឌូកាត់ដែលគេជំពាក់គាត់។ នាងប្រាប់បាសានីអូឲ្យទៅជួយមិត្តភក្តិរបស់គាត់ឲ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។ ទោះបីជាយ៉ាង

ណាក៏ដោយ ផតធៀទទូចសុំរឿងមួយៈ ពួកគេត្រូវតែរៀបការមុនពេលដែលបាសានីអូចាកចេញពីបិលម៉ុន។ ដូច្នេះ ពួកគេទាំងបួននាក់-ផតធៀ បាសានីអូ នេរីសា និង គ្រេនធីអានូ-ទៅព្រះវិហារភ្លាមមួយរំពេច ហើយរៀបការ។ បន្ទាប់មក បាសានីអូ និងគ្រេនធីអានូចាកចេញពីប្រពន្ធរបស់ពួកគេ ហើយត្រលប់ទៅវេនីសវិញ។

ផតធៀគិតឃើញពីវិធីដោះស្រាយបញ្ហាដ៏ល្អមួយ។ នាងចង់សង្គ្រោះជីវិតរបស់អាណូធីអូ ពីព្រោះគាត់មានចិត្តសប្បុរសចំពោះប្ដីរបស់គាត់ណាស់ គឺបាសានីអូ។ ចុងបញ្ចប់ នាងសរសេរសំបុត្រមួយច្បាប់ទៅបងជីដូនមួយរបស់នាង ដែលជាមេធាវីដ៏ឈ្លាសវៃ និងដ៏ល្បីល្បាញម្នាក់។ គាត់ឈ្មោះដុកទ័របិលឡារីអូ។ នាងសុំជំនួយពីគាត់ ហើយនាងក៏សុំគាត់ឲ្យនាងខ្ចីសម្លៀកបំពាក់មេធាវីមួយចំនួន។ លោកដុកទ័របិលឡារីអូបានផ្ញើសម្លៀកបំពាក់ឲ្យនាងភ្លាមៗ ហើយប្រាប់នាងពីវិធីជួយការពារអាណូធីអូនៅថ្ងៃកាត់ទោសគាត់។

ផតធៀបានសម្រេចចិត្តហើយថានាងនឹងធ្វើអ្វី។ នាងបានប្រាប់មិត្តភក្តិ និងអ្នកបម្រើរបស់នាងថានាងនឹងទៅឆ្ងាយពីរបីថ្ងៃដោយស្ងាត់ៗរហូតដល់ប្ដីរបស់នាងត្រលប់មកវិញ។ បន្ទាប់មក នាងប្រាប់នេរីសាពីផែនការរបស់នាង។ នាងបានសម្រេចចិត្តថាត្រូវទៅវេនីស ហើយនាងចង់ឲ្យនេរីសាទៅជាមួយនាងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ផតធៀមិនចង់ឲ្យនរណាម្នាក់ចំនាំនាងបាននៅពេលដែលនាងនៅទីនោះទេ ដូច្នេះនាង និងនេរីសាក៏ស្លៀកពាក់សម្លៀកបំពាក់ប្រុសៗ។ ពួកគេចាកចេញទៅវេនីសមើលទៅដូចជាបុរសវ័យក្មេងពីរនាក់អញ្ចឹង។

បាសានីអូ និងគ្រេនធីអានូបានមកដល់វេនីស ដែលថ្ងៃកាត់ទោសជិតមកដល់ នៅក្រោមការត្រួតត្រារបស់ឌុចនៃទីក្រុងវេនីស។ អាណូធីអូ និងស្សាយឡក់ត្រូវគេយកមកមុនឌុច។ ឌុចស្នើសុំឲ្យស្សាយឡក់បញ្ឈប់សំនើដ៏ឃោរឃៅរបស់គាត់ ហើយមិនឲ្យយកសាច់អាណូធីអូមួយផោននោះទេ។ ប៉ុន្តែស្សាយឡក់មិនយល់ព្រមនោះទេ។ អាណូធីអូបានធ្វើកិច្ចសន្យាហើយ ហើយអញ្ចឹងគាត់ត្រូវតែរក្សាវា គាត់បាននិយាយ។ បន្ទាប់មក បាសានីអូសុខចិត្តសងស្សាយឡក់នូវចំនួនលុយទ្វេដងដែលគេជំពាក់គាត់។ ស្សាយឡក់នៅតែមិនព្រមដោះលែងអាណូធីអូឡើយ។ "ច្បាប់នៃទីក្រុងវេនីសអនុញ្ញាតឲ្យខ្ញុំទាមទារយកសាច់របស់អាណូធីអូមួយផោន ពីព្រោះគាត់មិនគោរពពាក្យសន្យា។ ខ្ញុំស្អប់អាណូធីអូ ខ្ញុំនឹងមិនឲ្យគេបញ្ចុះបញ្ចូលបាននោះទេ។ ខ្ញុំសុខចិត្តយកសាច់របស់អាណូធីអូប្រសើរជាងយកលុយដែលគេឲ្យខ្ញុំ។"

ដោយបែរទៅរកឌុច ស្សាយឡក់និយាយថាៈ "តើលោកនឹងអនុញ្ញាតឲ្យខ្ញុំធ្វើនូវអ្វីដែលខ្ញុំមានសិទ្ធិធ្វើនោះទេ រឺក៏លោកមិនគោរពច្បាប់នៃទីក្រុងវេនីសទេ?"

**មេធាវីវ័យក្មេង**

ឌុចត្រូវតែទទួលស្គាល់ថាច្បាប់ពិតជាអនុញ្ញាតឲ្យស្សាយឡក់បដិសេធរឿងលុយជំនួសរឿងសាច់របស់អាណូធីអូ។ គាត់ចូលចិត្តអាណូធីអូ ប៉ុន្តែមិនហ៊ានចាត់ទុកគាត់ឲ្យខុសប្លែកពីប្រជាជនដទៃទៀត

ទេ។ ច្បាប់ចែងថានរណាម្នាក់ដែលធ្វើកិច្ចព្រមព្រៀងត្រូវតែរក្សាវាទុក។ ប្រសិនបើស្សាយឡុក់ទទួចសុំអញ្ចឹងហើយ អាណូធីអូត្រូវតែស្លាប់។ ស្សាយឡុក់ពិតជាបានទទួចសុំមែន។ គាត់បានគិតទៅកាន់ខ្លួនគាត់ "ចុងបញ្ចប់ខ្ញុំនឹងមានលទ្ធភាពចាត់ទុកអាណូធីអូតាមវិធីដែលគាត់សក្តិសមនឹងទទួល។ ខ្ញុំមិនអាណិតគាត់ទាល់តែសោះ។ ពាណិជ្ជករដ៏មានមោទនៈនេះតែងតែស្អប់ខ្ញុំ ហើយធ្វើឲ្យអ្នកដទៃស្អប់ខ្ញុំផងដែរ។ ខ្ញុំនឹងមិនលើកលែងទោសឲ្យគាត់ឡើយ។"

ឌុចបានសរសេរសំបុត្រផ្ញើទៅមេធាវីដ៏ល្បីល្បាញម្នាក់រួចទៅហើយ ដោយសុំឲ្យគាត់មកវេនីសដើម្បីទូន្មានគាត់ពីបញ្ហាដ៏លំបាកនេះ។ មនុស្សដែលគាត់សរសេរសំបុត្រទៅឲ្យគឺដុកទ័របិលឡារីអូ-បងជីដូនមួយរបស់ផតធៀ ដែលបានបង្ហាញនាងពីរបៀបការពារអាណូធីអូ។ ខណៈពេលដែលស្សាយឡុក់មិនបង្ហាញពីក្តីមេត្តាចំពោះអាណូធីអូនោះ ឌុចសម្រេចចិត្តនៅចាំលោកដុកទ័របិលឡារីអូ។ គាត់គិតថា៖ "ប្រហែលជាមេធាវីដ៏ឈ្លាសវៃម្នាក់អាចរកឃើញវិធីជួយសង្គ្រោះជីវិតរបស់អាណូធីអូ"។

ស្រាប់តែពេលដែលឌុចសម្រេចចិត្តធ្វើដូចនេះ ស្មៀនម្នាក់បានដើរចូលមក។ គេនិយាយថាគេបានយកសំបុត្រមួយច្បាប់ផ្ញើមកពីលោកបិលឡារីអូ។ នៅក្នុងសំបុត្រនេះ ដុកទ័របិលឡារីអូបានសរសេរថាគាត់មានជំងឺ ហើយនឹងគ្មានលទ្ធភាពមកទេ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានស្នើសុំថាតើមិត្តភក្តិមេធាវីវ័យក្មេងម្នាក់របស់គាត់អាចមកជំនួសបានរឺក៏អត់។ ឌុចយល់ព្រមធ្វើដូចដែលដុកទ័របិលឡារីអូបានស្នើសុំ ហើយគាត់បានអញ្ជើញឲ្យមេធាវីវ័យក្មេងនោះចូលមកក្នុង។

ស្មៀនដែលនាំសំបុត្រយកឲ្យឌុចគឺពិតជានេរីសា ដែលស្លៀកពាក់ជាបុរស។ មេធាវីវ័យក្មេងនោះប្រាកដជាផតធៀ ដែលស្លៀកពាក់សម្លៀកបំពាក់មេធាវីដែលដុកទ័របានឲ្យនាងខ្ចី។ ឌុចមានការភ្ញាក់ផ្អើលណាស់នៅពេលដែលគាត់ឃើញថាមេធាវីម្នាក់នេះនៅក្មេងអ្វីម្ល៉េះទេ ប៉ុន្តែគាត់ស្នើសុំឲ្យគាត់ការពារអាណូធីអូ។

ផតធៀបែរទៅរកស្សាយឡុក់ ហើយស្នើសុំឲ្យគាត់បង្ហាញក្តីមេត្តាចំពោះអាណូធីអូ។ "ក្តីមេត្តា" នាងបាននិយាយ "ឲ្យរង្វាន់មិនមែនត្រឹមតែមនុស្សដែលទទួលវានោះទេ ប៉ុន្តែក៏ចំពោះមនុស្សដែលផ្តល់វាដែរ។ យើងបន់ស្រន់ចំពោះព្រះ ដោយសង្ឃឹមថាព្រះនឹងបង្ហាញក្តីមេត្តាដល់យើង ហើយយើងគួរតែផ្តល់ក្តីមេត្តាដល់មនុស្សឯទៀត។" ប៉ុន្តែស្សាយឡុក់មិនស្តាប់សម្តីនាងនោះទេ។

"ខ្ញុំត្រឹមតែអាចស្នើសុំឲ្យសងវិញនូវអ្វីដែលគេជំពាក់ខ្ញុំប៉ុណ្ណោះ" គាត់បាននិយាយ។

"តើគាត់អាចសងវិញនូវប្រាក់ដែលលោកឲ្យគេខ្ចីនោះទេ?" ផតធៀបានសួរ។

បាសានីអូបាននិយាយយ៉ាងរហ័សរហួនថា៖ "គាត់អាចសងបាន ហើយគាត់សុខចិត្តបង់លុយថែមទៀតផង។ ខ្ញុំអាចបង់លុយដប់ដងលើសហ្នឹងសម្រាប់អាណូធីអូ។" បាសានីអូអង្វរឲ្យមេធាវីនោះបំភ្លេចចោលនូវពាក្យច្បាប់ដែលជាក់លាក់នោះចោល ក្នុងគោលបំណងដើម្បីសង្គ្រោះជីវិតមនុស្សម្នាក់។

"ទេ" ផតធៀបាននិយាយ "ខ្ញុំមិនអាចអនុញ្ញាតរឿងនេះបានទេ។ ប្រសិនបើយើងមិនទទូចថាមនុស្សនេះគោរពច្បាប់នៅពេលឥលូវនេះទេ មនុស្សដទៃទៀតនឹងធ្វើតាមគំរូអាក្រក់របស់គាត់ ហើយប្រទេសទាំងមូលនឹងទទួលការប្រមាថមើលងាយ។"

ស្យាយឡុក់រីករាយណាស់ នៅពេលដែលគាត់ឮចម្លើយនេះ។ "អូ ចៅក្រមវ័យក្មេងអ្វីក៏ឆ្លាតម្ល៉េះទេ!" គាត់បានស្រែក យ៉ាងរីករាយ។ គាត់បានរំពឹងទុកថាការកាត់ក្តីនឹងបញ្ចប់ក្នុងពេលឆាប់ៗនេះ។ គាត់សរសើរមេធាវីវ័យក្មេងនេះ ហើយសើចដាក់អាណូធីអូ។ បន្ទាប់មក ផតធៀសុំមើលកិច្ចព្រមព្រៀងរវាងអាណូធីអូ និងស្យាយឡុក់ែដលបានចុះហត្ថលេខា។ នាងបានអានវា ហើយយល់ព្រមថាស្យាយឡុក់អាចយកសាច់មួយផោនរបស់គាត់បាន។ បន្ទាប់មកផតធៀបែរទៅរកអាណូធីអូ ហើយបញ្ជាឲ្យគាត់ដោះអាវបង្ហាញទ្រូងរបស់គាត់។ ស្យាយឡុក់បានរៀបចំខ្លួននឹងសម្លាប់គាត់រួចរាល់ហើយ។ គាត់បានស្រែកថាៈ "អូ ចៅក្រមអភិជន! អូ បុរសវ័យក្មេងដ៏អស្ចារ្យ!"

អាណូធីអូបានគិតរួចជាស្រេចហើយថាគាត់នឹងស្លាប់។ គាត់និយាយលាគ្នាទៅមិត្តភក្តិរបស់គាត់បាសានីអូ ហើយសុំឲ្យគាត់ប្រាប់ផតធៀពីមូលហេតុដែលគាត់ស្លាប់ផង។ បាសានីអូមិនសប្បាយចិត្តទាល់តែសោះ ហើយគាត់បានឆ្លើយតបថាគាត់នឹងឲ្យអ្វីៗគ្រប់យ៉ាងដែលគាត់មានដើម្បីជួយសង្គ្រោះអាណូធីអូប្រសិនបើគាត់អាចធ្វើបាន។ គាត់ថែមទាំងសុខចិត្តលះបង់ជីវិតខ្លួនគាត់ដើម្បីជួយអាណូធីអូទៀតផង។

"ឥលូវ" ផតធៀនិយាយទៅកាន់ស្យាយឡុក់ "យកសាច់មួយផោនដែលគេជំពាក់លោកទៅ។ កាត់វាចេញពីទ្រូងរបស់បុរសនេះទៅ។"

ស្យាយឡុក់មានកាំបិតនៅក្នុងដៃខណៈពេលដែលគាត់ដើរមកមុខ។ គាត់រៀបចំខ្លួនរួចជាស្រេចហើយដើម្បីកាត់យកបេះដូងរបស់អាណូធីអូ។ "អូ ចៅក្រមដ៏ឈ្លាសវៃ! អូ ចៅក្រមវ័យក្មេងដ៏ឈ្លាសវៃអើយ!" គាត់បានស្រែក។ គាត់បានស្រែកទៅកាន់អាណូធីអូថាៈ "រៀបចំខ្លួនឯងទៅ!"

## ស្យាយឡុក់ត្រូវចាញ់ក្តី

មុនពេលដែលគាត់អាចប្រើប្រាស់កាំបិតរបស់គាត់ដើម្បីកាត់ស្បែករបស់អាណូធីអូសូម្បីតែបន្តិចនោះ ផតធៀបានបញ្ឈប់គាត់។

"ឈប់សិន!" នាងបាននិយាយ។ "ខ្ញុំនៅមានរឿងទៀតត្រូវនិយាយ។ ពាក្យក្នុងកិច្ចសន្យានេះនិយាយយ៉ាងច្បាស់លាស់ថាលោកនឹងយក "សាច់មួយផោន"។ ប៉ុន្តែវាមិនបាននិយាយថាលោកនឹងយកឈាមសូម្បីមួយតំណក់ឡើយ។ លោកនឹងយកសាច់របស់អាណូធីអូបាន ប៉ុន្តែប្រសិនបើលោកធ្វើឲ្យស្រក់ឈាមមួយតំនក់នោះ អញ្ចឹងទ្រព្យសម្បត្តិរបស់លោកទាំងប៉ុន្មាននឹងត្រូវតែប្រគល់ឲ្យទៅរដ្ឋ។ នេះជាច្បាប់នៃទីក្រុងវេនីស។"

ស្យាយឡុក់ឈរនៅស្ងៀមដោយមិនកម្រើកអ្វីបន្តិចសោះ។ គាត់មានការភ្ញាក់ផ្អើល ហើយម៉ូរមៅយ៉ាងខ្លាំងដែលគាត់អាចនិយាយបានដោយលំបាកលំបិន។ "តើនោះជាអ្វីដែលច្បាប់បានចែង

រឺ?″ គាត់បានសួរ។ ផតធៀបានបង្ហាញគាត់នូវច្បាប់ចំពោះមាត្រានេះ។ គ្រេនធីអានូអាចមើលដឹងបានថាស្យាយឡក់ខឹងអ្វីម្ល៉េះទេ ហើយឥលូវគាត់ស្រែកឡើងថាៈ ‶អូ ចៅក្រមដ៏ឈ្លាសវៃ! ឃើញទេស្យាយឡក់ គាត់ជាចៅក្រមដ៏ឆ្លាតម្លេះទេ!″

បន្ទាប់មក ស្យាយឡក់ចាំថាបាសានីអូសុខចិត្តសងលុយវិញ ហើយថែមទាំងឲ្យលើសហ្នឹងទៀតផង។ ‶ខ្ញុំនឹងទទួលយកសំនើរបស់ឯង″ គាត់និយាយទៅកាន់បាសានីអូ។ ‶សងលុយវិញឲ្យបានបីដងលើសលុយដែលយើងបានឲ្យអាណូធីអូខ្ចីមក ហើយបន្ទាប់មក ខ្ញុំនឹងដោះលែងគាត់។″

‶នេះ នៅទីនេះ″ បាសានីអូបាននិយាយ ដោយកាន់លុយយកចេញមកក្រៅ។ ប៉ុន្តែផតធៀមិនអនុញ្ញាតដូច្នេះឡើយ។ មុនពេលបន្តិចកន្លងទៅនេះ ស្យាយឡក់ប្រកែកមិនព្រមយកលុយទេ ដូច្នេះឥលូវគាត់គួរតែគ្មានអ្វីឡើយ នាងបាននិយាយ។

ស្យាយឡក់ ដោយខឹងយ៉ាងខ្លាំង បំរុងតែនឹងចាកចេញទៅហើយ បែរជាផតធៀហៅគាត់ឲ្យត្រលប់មកវិញ។ ‶ឈប់សិន!″ នាងបាននិយាយ។ ‶នៅមានច្បាប់មួយទៀតដែលយើងត្រូវតែចងចាំ។ ប្រសិនបើនរណាម្នាក់មានគម្រោងចង់សម្លាប់ប្រជាជនណាម្នាក់នៃទីក្រុងវេនីស ទ្រព្យសម្បត្តិរបស់គាត់ពាក់កណ្តាលត្រូវប្រគល់ឲ្យទៅប្រជាជនម្នាក់នោះ។ ពាក់កណ្តាលទៀតត្រូវប្រគល់ជូនរដ្ឋ។ ហើយឌុចនឹងបញ្ជាឲ្យធ្វើទណ្ឌកម្មផ្សេងៗទៀតដែលគាត់គិតថាត្រឹមត្រូវ។ លុតជង្គង់ពីមុខគាត់ ហើយសុំការសន្តោសប្រណីទៅ។″

ថ្មីៗនេះ ស្យាយឡក់បានបដិសេធចោលនូវការសន្តោសប្រណីចំពោះអាណូធីអូដែលឥលូវគាត់មិនអាចរំពឹងទុកនូវការសន្តោសប្រណីចំពោះខ្លួនគាត់ឡើយ។ ប៉ុន្តែឌុចមិនសាហាវយង់ឃ្នងដូចអ្នកចងការប្រាក់ម្នាក់នេះទេ។

‶យើងនឹងបង្ហាញឯងថាមនុស្សអាចមានចិត្តល្អចំពោះគ្នាទៅវិញទៅមកច្រើនជាងដែលឯងគិតទៅទៀត។ ឯងនឹងមិនបាត់បង់ជីវិតឡើយ ខ្ញុំនឹងប្រាប់ឯងពីរឿងនេះសូម្បីតែមុនពេលដែលឯងសុំយើងឲ្យទុកជីវិតឲ្យទៅទៀត។ ប៉ុន្តែឯងត្រូវតែប្រគល់ទ្រព្យសម្បត្តិ និងលុយរបស់ឯងពាក់កណ្តាលឲ្យទៅអាណូធីអូ ហើយពាក់កណ្តាលទៀតទៅរដ្ឋ។″

ហើយឥលូវ អាណូធីអូបានបង្ហាញនូវក្តីមេត្តាចំពោះអ្នកចងការប្រាក់ម្នាក់នេះ។ ‶ខ្ញុំនឹងមកយកចំនែកទ្រព្យសម្បត្តិរបស់ស្យាយឡក់នោះទេ។ ប៉ុន្តែគាត់ត្រូវតែក្លាយជាអ្នកកាន់សាសនាគ្រិស្ត″ គាត់បាននិយាយ។

ស្យាយឡក់ក៏ត្រូវគេបង្ខំឲ្យចុះហត្ថលេខាលើសំបុត្របណ្តាំមួយច្បាប់ដែរ។ សំបុត្រនេះនឹងនិយាយថាចេស៊ីកា កូនស្រីរបស់គាត់ និងឡូរិនហ្ស បុរីរបស់នាង គួរតែទទួលយកនូវទ្រព្យរបស់ស្យាយឡក់ទាំងអស់នៅពេលដែលគាត់ស្លាប់បាត់ទៅ។ ឡូរិនហ្សគឺជាមិត្តភក្តិដ៏ល្អម្នាក់របស់អាណូធីអូ។ មិនយូរប៉ុន្មានកន្លងទៅ ចេស៊ីកាបានរត់ចេញពីឪពុករបស់នាង ហើយរៀបការជាមួយនឹងឡូរិនហ្ស ដែលជាអ្នកកាន់សាសនាគ្រិស្ត យ៉ាងស្ងាត់ៗ។ នាងបានយកលុយ និងគ្រឿងអលង្ការមួយ

ចំនួនតាមខ្លួននៅពេលដែលនាងចាកចេញពីផ្ទះ ហើយស្យាយឡុក់ខឹងខ្លាំងណាស់។ មុនដំបូង គាត់អាចត្រឹមតែស្រែកថាៈ "កូនស្រីរបស់ខ្ញុំ! អូ លុយរបស់ខ្ញុំ! អូ កូនស្រីរបស់ខ្ញុំ! នាងពង្រាត់គ្នាជាមួយនឹងអ្នកកាន់សាសនាគ្រិស្តហើយ! តើច្បាប់ជួយខ្ញុំយ៉ាងម៉េចទៅ? អូ លុយរបស់ខ្ញុំ កូនស្រីរបស់ខ្ញុំ!" ស្យាយឡុក់ហាក់ដូចជាព្រួយបារម្ភពីលុយដូចគាត់ព្រួយបារម្ភពីកូនស្រីគាត់អញ្ចឹងដែរ។ អ្នកចងការប្រាក់ម្នាក់នេះបាននិយាយថាគាត់នឹងមិនទុកលុយឲ្យចេស៊ីកាសូម្បីតែបន្តិចឡើយនៅពេលដែលគាត់ស្លាប់ទៅ ហើយគាត់នឹងមិនអនុគ្រោះឲ្យនាងឡើយ។

ឥលូវ ជនជាតិជ្វីហ្វម្នាក់នេះបានដឹងថាគាត់ត្រូវតែស្តាប់បញ្ជារបស់អាណូធីអូ និងផតធៀ។ "ខ្ញុំឈឺហើយ" គាត់បានស្រែក។ "ឲ្យខ្ញុំទៅផ្ទះទៅ។ ផ្ញើកិច្ចសន្យាទៅផ្ទះរបស់ខ្ញុំទៅ។ ខ្ញុំនឹងចុះហត្ថលេខា។"

ដូច្នេះ ឌុចក៏ដោះលែងស្យាយឡុក់ ហើយការកាត់ក្តីត្រូវបានបញ្ចប់។

## ល្បិចរបស់ផតធៀ

ក្នុងកំឡុងពេលកាត់ក្តី អ្នករាល់គ្នាពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានឃើញថាមេធាវីម្នាក់នេះពិតជាមានវ័យក្មេង ហើយឈ្លាសវៃម្ល៉េះទេ។ ប៉ុន្តែគ្មាននរណាម្នាក់សង្ស័យថាមេធាវីម្នាក់នេះពិតជាផតធៀសោះឡើយ។ សូម្បីបាសានីអូក៏មិនដឹងដែរ។ ផតធៀបានផ្លាស់ប្តូរសម្លេង និងរូបរាងរបស់នាងយ៉ាងឈ្លាសវៃដែលសូម្បីតែប្តីរបស់នាងផ្ទាល់ក៏មិនចំនាំនាងបានដែរ។

បាសានីអូ និងអាណូធីអូចង់បង្ហាញមេធាវីវ័យក្មេងម្នាក់នេះថាពួកគេមានការដឹងគុណយ៉ាងខ្លាំងចំពោះជំនួយរបស់គាត់។ "សូមទទួលយកលុយ៣០០០ឌូកាត់ដែលខ្ញុំជំពាក់ស្យាយឡុក់ចុះ" អាណូធីអូនិយាយ។ ប៉ុន្តែផតធៀមិនព្រមទទួលយកលុយទេ។ បាសានីអូក៏មានការព្រួយបារម្ភនឹងឲ្យអ្វីទៅមេធាវីដែរ។ អញ្ចឹងផតធៀគាត់ថា នាងនឹងបញ្ឆោតប្តីរបស់នាង ធ្វើជារឿងកំប្លែង។ "ប្រសិនបើអ្នកទទូចសុំទៅហើយ ឲ្យស្រោមដៃមកខ្ញុំមក" នាងប្រាប់បាសានីអូ។ បាសានីអូដោះស្រោមដៃរបស់គាត់ចេញ ដោយបង្ហាញចិញ្ចៀននៅលើម្រាមដៃរបស់គាត់។ "ទុកជាសញ្ញានៃការដឹងគុណរបស់លោក ឲ្យចិញ្ចៀននៅលើម្រាមដៃរបស់លោកមកខ្ញុំមក។" ភ្លាមនោះ បាសានីអូក៏គេរវាសដៃចេញឆ្ងាយ។ ចិញ្ចៀននេះគឺជាចិញ្ចៀនដែលផតធៀឲ្យគាត់នៅពេលដែលនាងសន្យាថានឹងរៀបការជាមួយគាត់។ គាត់បានសន្យាថានឹងមិនដោះវាចេញនោះទេ។ គាត់ធ្វើពុតថាចិញ្ចៀននេះគ្មានតម្លៃ ហើយស្ទួចស្ទើងពេកហើយសម្រាប់ឲ្យជាអំណោយនោះ។ ប៉ុន្តែផតធៀសុំវាម្តងទៀត។ បន្ទាប់មក បាសានីអូបានប្រាប់នាងថាវាជាចិញ្ចៀនរបស់ប្រពន្ធគាត់ ហើយនាងបានឲ្យគាត់សន្យាថានឹងមិនដោះវាចេញនោះឡើយ។

"នោះជាពាក្យដោះសាដ៏សាមញ្ញមួយ" ផតធៀបានឆ្លើយតប។ "នោះជាអ្វីដែលបុរសនិយាយនៅពេលដែលពួកគេមិនចង់ឲ្យអំណោយ។ ប្រពន្ធរបស់លោកនឹងមិនខឹងយូរទេ។ លោកអាចប្រាប់នាងបានថាតើខ្ញុំសក្តិសមនឹងទទួលវាប៉ុណ្ណា។"

ផតធៀ និងនេរីសា ដោយនៅតែស្លៀកពាក់សម្លៀកបំពាក់មេធាវីនៅឡើយ បែរខ្លួននឹងចេញទៅ។ ស្ទើរតែភ្លាមនោះ អាណូធីអូបានបញ្ចុះបញ្ចូលឲ្យបាសានីអូបោះបង់ចិញ្ចៀននោះ។ បាសានីអូមានអារម្មណ៍បោរមុខដោយហាក់ដូចជារមិលគុណគេ អញ្ចឹងគាត់ក៏ឲ្យវាទៅផតធៀ។ នេរីសាក៏បានរៀបចំបញ្ចុះបញ្ចូលគ្រេនធីអានូឲ្យប្រគល់ចិញ្ចៀនដែលនាងបានឲ្យគាត់ដែរ។ គាត់ក៏បានសន្យាថានឹងមិនដោះវាចេញដែរ។

ផតធៀ និងនេរីសាចាកចេញពីទីក្រុងវេនីស ហើយធ្វើដំណើរឲ្យបានលឿនជាទីបំផុតតាមដែលអាចធ្វើបានទៅបិលម៉ុន។ ពួកគេចង់ឲ្យទៅដល់ទីនោះមុនពេលដែលប្ដីរបស់ពួកគេត្រលប់មកវិញ។ នៅពេលដែលពួកគេទៅដល់ផ្ទះរបស់ផតធៀវិញ ពួកគេផ្លាស់សម្លៀកបំពាក់មួយរំពេច។ មិនយូរប៉ុន្មាន ពួកគេកំពុងតែអង្គុយចុះ ដោយស្លៀកពាក់ក្នុងសម្លៀកបំពាក់ធម្មតារបស់ពួកគេ រង់ចាំប្ដីរបស់ពួកគេត្រលប់មករកពួកគេវិញ។ មិនយូរប៉ុន្មានក្រោយមក បុរសទាំងពីរនាក់ក៏មកដល់ ជាមួយនឹងអាណូធីអូ។ បាសានីអូណែនាំអាណូធីអូឲ្យប្រពន្ធគាត់ស្គាល់។ "នេះជាមិត្តភក្ដិ" គាត់បានប្រាប់នាង "ដែលបានជួយបងច្រើនណាស់។" អញ្ចឹងផតធៀស្វាគមន៍អាណូធីអូមកកាន់ផ្ទះរបស់នាង។

ខណៈពេលដែលនាងកំពុងតែធ្វើដូចនេះ នាងបានឃើញគ្រេនធីអានូ និងនេរីសាកំពុងតែឈ្លោះប្រកែកគ្នានៅជ្រុងម្ខាងនៃបន្ទប់។ "មានរឿងអ្វីកើតឡើង?" ផតធៀបានស្រែក។ "ឈ្លោះគ្នាហើយរឺនៅ? មានបញ្ហាអ្វី?"

"យើងកំពុងតែឈ្លោះគ្នាពីរឿងចិញ្ចៀនដែលនេរីសាបានឲ្យមកខ្ញុំ" គ្រេនធីអានូបានពន្យល់។ "ចិញ្ចៀននោះមានពាក្យសរសេរថា៖ «ស្រលាញ់ខ្ញុំ ហើយកុំចាកចេញពីខ្ញុំ»។"

"ខ្ញុំម៉ូរម៉ៅព្រោះថាគ្រេនធីអានូបានសន្យាយ៉ាងស្មោះត្រង់ថាគាត់នឹងរក្សាវាទុក" នេរីសាបាននិយាយ "ហើយឥលូវគាត់បានយកវាទៅឲ្យស្មៀនរបស់មេធាវីម្នាក់ទៅហើយ។ វាមិនសំខាន់ទេថាតើវាមានតម្លៃរឺក៏អត់នោះ។ គាត់មិនគួរដោះវាចេញនោះទេ។"

## អ្វីៗគ្រប់យ៉ាងត្រូវរៀបរយឡើងវិញ

ឥលូវ ផតធៀបានប្ដេជ្ញានឹងពេញចិត្តល្បិចកលដែលនាងបានធ្វើមកលើប្ដីរបស់នាងហើយ។ "ជាការពិតណាស់ គ្រេនធីអានូខុសដែលបានយកអំនោយប្រពន្ធទីមួយរបស់ខ្លួនចេញ។ ខ្ញុំក៏ឲ្យចិញ្ចៀនទៅប្ដីរបស់ខ្ញុំដែរ ហើយបានឲ្យគាត់សន្យាថានឹងរក្សាវាទុក។ ប្រសិនបើគាត់ដោះវាចេញ ខ្ញុំប្រាកដជាខឹងនឹងគាត់មិនខានឡើយ។"

បន្ទាប់មកគ្រេនធីអានូឆ្លើយតបថា៖ "ប៉ុន្តែបាសានីអូបានដោះចិញ្ចៀនចេញដែរតើ-គាត់បានប្រគល់វាឲ្យទៅមេធាវីវ័យក្មេងដែលបានសុំវា។ ហើយបន្ទាប់មកក្មេងប្រុសនោះ ដែលត្រូវជាស្មៀន សុំចិញ្ចៀនរបស់ខ្ញុំ។"

នៅពេលដែលនាងឮដូចនេះ ផតធៀធ្វើពុតជាខឹងយ៉ាងខ្លាំង។ នាងបានសួរបាសានីអូថា៖ "តើចិញ្ចៀនមួយណាដែលបងឲ្យគេ? ខ្ញុំសង្ឃឹមថាវាមិនមែនជាចិញ្ចៀនដែលបងទទួលយកពីខ្ញុំនោះទេ។"

បាសានីអូមិនសប្បាយចិត្តឡើយ នៅពេលដែលគាត់ឃើញថាប្រពន្ធរបស់គាត់ខឹងអ្វីម្ល៉េះទេ។ ប៉ុន្តែគាត់ត្រូវតែសារភាព ហើយប្រាប់នាងថាគាត់បានដោះវាចេញមែន។ "អូនដឹងទេថាបងទាស់ចិត្តយ៉ាងណាក្នុងការឲ្យចិញ្ចៀនទៅបុរសនោះ ហើយពីមូលហេតុដែលបងឲ្យចិញ្ចៀនទៅគេ។

ប៉ុន្តែផតធៀនៅតែធ្វើពុតជាខឹង។ នាងចោទថាគាត់ឲ្យចិញ្ចៀនទៅស្ត្រីម្នាក់។ បាសានីអូគិតថាផតធៀប្រាកដជាគិតថាគាត់ពិតជាចិត្តអាក្រក់មែន។ គាត់បានប្រាប់នាងថាគាត់បានឲ្យចិញ្ចៀនទៅមេធាវីនោះព្រោះគេមានគុណចំពោះគាត់ណាស់ក្នុងការជួយសង្គ្រោះជីវិតរបស់អាណូធីអូ។ "ប្រសិនជាអូននៅទីនោះ" គាត់បាននិយាយ "បងគិតថាអូននឹងប្រាប់បងឲ្យប្រគល់ចិញ្ចៀនទៅគេហើយ។"

បន្ទាប់មក អាណូធីអូបែរទៅរកផតធៀហើយនិយាយថា៖ "ជម្លោះដ៏សៅហ្មងទាំងអស់នេះសុទ្ធតែបង្កឡើងដោយសារតែខ្ញុំទាំងអស់!"

"កុំចាត់ទុករឿងនេះជារឿងធំដុំអី" ផតធៀបានឆ្លើយតប។ នាងបានយកចិញ្ចៀនពីកាបូបរបស់នាង ហើយនិយាយថា៖ "ឲ្យចិញ្ចៀននេះទៅគាត់ទៅ ហើយប្រាប់ឲ្យគាត់រក្សាវាទុកឲ្យបានល្អជាងដែលគាត់រក្សាទុកលើកមុន។"

អាណូធីអូយកចិញ្ចៀនទៅឲ្យបាសានីអូ ដែលសម្លឹងមើលវា។ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយឃើញថានេះហើយជាចិញ្ចៀនដែលគាត់បានឲ្យទៅគេ។ បន្ទាប់មក ផតធៀបានបង្ហាញប្តីនាងនូវសំបុត្រដែលផ្ញើពីដុកទ័របិលឡារីអូ ហើយអញ្ចឹងគាត់ក៏ដឹងថាមេធាវីដ៏ឈ្លាសវៃនោះពិតជាផតធៀ ប្រពន្ធរបស់គាត់មែន។ បាសានីអូបានដឹងថាភាពវៃឆ្លាត និងភាពក្លៀវក្លារបស់ប្រពន្ធគាត់បានជួយសង្គ្រោះមិត្តសម្លាញ់របស់គាត់អាណូធីអូ។ គាត់មានការភ្ញាក់ផ្អើល ហើយសប្បាយចិត្តយ៉ាងខ្លាំង។

មិនយូរប៉ុន្មានក្រោយមក អាណូធីអូបានទទួលដំណឹងល្អពីរឿងផ្ទាល់ខ្លួនរបស់គាត់។ ផតធៀហុចឲ្យគាត់នូវសំបុត្រមួយចំនួនដែលទើបតែមកដល់។ សំបុត្រទាំងនេះប្រាប់អាណូធីអូថាកប៉ាល់ដែលគាត់គិតថាបានបាត់នោះបានត្រលប់មកវេនីសវិញហើយ ហើយបាននាំយកនូវទំនិញដ៏មានតម្លៃរបស់ពួកគេមកវិញ។ អាណូធីអូក្លាយជាអ្នកមានស្តុកស្តម្ភម្នាក់ឡើងវិញ។

ដូច្នេះរឿងពាណិជ្ជករទីក្រុងវេនីសបានបញ្ចប់-ដោយមានដំណឹងល្អសម្រាប់ពាណិជ្ជករម្នាក់នេះ ហើយនឹងសំណើចរវាងប្តី និងប្រពន្ធចំពោះរឿងកំប្លែងអំពីរឿងចិញ្ចៀន។

**ចប់ដោយបរិបូណ៌**